# បង្កើនជីជាតិដីឱ្យកាន់តែល្អប្រសើរឡើង

## ១-តួនាទីរបស់ដី

ដំណាំស្រូវស្រូបយកទឹកយ៉ាងច្រើនតាមរយៈឫស  ហើយដោយសារឫសត្រូវការដកដង្ហើម វាក៏ត្រូវការឱ្យមានខ្យល់អុកស៊ីសែន ក្នុងបរិមាណគ្រប់គ្រាន់ គ្រប់ពេលវេលាដែរ។ ដើម្បីផ្តល់ទឹក និងខ្យល់បានដល់ឫសស្រូវ ដីត្រូវមានលក្ខណៈរូបសមស្រប (អាចឱ្យទឹកជ្រាបចូល អាចរក្សាទឹក អាចឱ្យខ្យល់ចូលបាន ។ល។

ដំណាំស្រូវត្រូវការស្រូបយកអាហារចិញ្ចឹមចាំបាច់ភាគច្រើនពីដីដើម្បីធំលូតលាស់ ប្រសិនបើសារធាតុចិញ្ចឹមពុំគ្រប់គ្រាន់ស្រូវពុំអាចលូតលាស់បានល្អទេ ។ ដីជូរ និងសារធាតុពុលមួយចំនួនក៏បង្អាក់ដំណើរលូតលាស់របស់ស្រូវដែរ ។

ដូច្នេះលក្ខណៈគីមីរបស់ដី គឺមានសារៈសំខាន់ជាអាយុជីវិតសំរាប់ការលូតលាស់របស់ស្រូវ ហើយលក្ខណៈរូប និង ជីវសាស្ត្ររបស់ដី ក៏មានតួនាទីដូចគ្នាដែរ ។

នៅក្នុងដីមានអតិសុខុមប្រាណ និងសត្វល្អិតតូចៗជាច្រើនដូចជា ជន្លេនរស់នៅក្នុងដី ហើយដើរតួនាទីដ៏សំខាន់ ឫសស្រូវជញ្ជ្រាំង និងកាកសំណល់ផ្សេងៗដែលបន្សល់ក្រោយពេលប្រមូលផលបានធ្លាក់កប់ទៅដី សុទ្ធតែត្រូវរំលាយដោយអតិសុខុមប្រាណរបស់ដី ក្លាយទៅជាសារធាតុអសរីរាង្គផ្តល់ឱ្យដី ។ ជាមួយនេះដែរអតិសុខុមបាណរបស់ដីជាច្រើនមានឥទ្ធិពលបង្អាក់ការលូតលាស់នៃបាក់តេរីចង្រៃដែលបង្កជំងឺដល់ស្រូវ ។

ដូច្នេះលក្ខណៈគីមី រូប និងជីវសាស្ត្ររបស់ដីមានការទំនាក់ទំនងគ្នា ហើយមានឥទ្ធិពលលើគ្នាទៅវិញទៅមក ។



## ២-មូលហេតុដែលដីបាត់ជីជាតិ (លក្ខណៈរូប គីមី និងជីវសាស្ត្រ)

-មិនតុល្យភាពនៃការយកផលចំណេញពីដី នឹងការដាក់សារធាតុសរីរាង្គ និងសារធាតុចិញ្ចឹមទៅឱ្យដី

-ធ្វើស្រែច្រើនដងក្នុង ១ឆ្នាំ ហើយពុំបានផ្តល់សារធាតុសរីរាង្គ និងជីឱ្យគ្រប់គ្រាន់ទៅដីវិញ។ ក្នុង១ឆ្នាំៗកសិករបាន ទាញយកផលស្រូវពីដីជាមធ្យម ៣-៥តោន/ហិកតា ហើយដើម្បីបង្កើតបានជាផលស្រូវ ៣-៥តោន ស្រូវត្រូវការស្រូបយក សារធាតុសរីរាង្គ និងជីពីក្នុងដីរាប់តោន ដូច្នេះនៅពេលដែលកសិករពុំបានផ្តល់នូវសារធាតុសរីរាង្គគ្រប់គ្រាន់ទៅឱ្យដីធ្វើឱ្យដី ខ្សោះជីជាតិ និងបាត់លក្ខណះរូប

-ប្រើប្រាស់ជីគីមី ដោយពុំដាក់បន្ថែមជីសារធាតុសរីរាង្គ (ជីធម្មជាតិ ជីកំប៉ុស្តិ៍)

-មានការសឹករិក ដោយសារការហូរច្រោះលើផ្ទៃដីស្រែនិង ធ្វើស្រូវតែមួយមុខ មិនឆ្លាស់មុខដំណាំ

## ៣-ការគ្រប់គ្រងជីជាតិដីដូឱ្យកាន់តែល្អប្រសើរ

ដើម្បីថែរក្សាសមត្ថភាពផលិតកម្មនៃដីស្រែ ការចាំបាច់គឺពុំមែនគ្រាន់តែផ្តល់នូវបរិមាណសារធាតុអាហារចិញ្ចឹមឱ្យ គ្រប់គ្រាន់ដល់ដីនោះទេ គឺថែមទាំងត្រូវរក្សានូវសមត្ថភាពចាប់អាហារចិញ្ចឹម និងអតិសុខុមប្រាណរបស់ដីឱ្យស្ថិតក្នុងលក្ខខ័ណ្ឌ សមស្របផងដែរ ក្នុងគោលបំណងនេះមធ្យោបាយដ៏មានប្រសិទ្ធិភាពបំផុតគឺ កែលំអរលក្ខណៈរូប លក្ខណៈគីមី និងលក្ខណៈ ជីវសាស្ត្ររបស់ដី ដោយត្រូវអនុវត្តដូចខាងក្រោម ៖

- **បន្ថែមនូវអង្គធាតុសរីរាង្គឱ្យបានច្រើនជារៀងរាល់ឆ្នាំ**

- ធ្វើស្រែត្រូវបន្ថែមជីគីមីឱ្យបានតាមតំរូវការរបស់ស្រូវ ពេលនោះស្រូវទទួលផលល្អ គេនឹងទទួលបានជញ្ជ្រាំង ឬ ចំបើងច្រើនត្រូវភ្ជួរលប់បង្កប់ទៅក្នុងដីក្រោយពេលច្រូតកាត់រួច។
- ត្រូវធ្វើការដាំដំណាំសណ្តែកមុនដើមរដូវវស្សា ពិសេសលើប្រភេទដីខ្សាច់ និងល្បាយខ្សាច់
- ត្រូវដាក់ជីកំប៉ុស្តិ៍ឬ ជីធម្មជាតិ ជារៀងរាល់ឆ្នាំទៅដីស្រែជាមធ្យម ៥00គ.ក្រ/១0អាដោយលាយឱ្យស្មើរួច ភ្ជួរលប់ភ្លាម។

- **បន្ថែមនូវសារធាតុចិញ្ចឹមឱ្យដីឱ្យបានគ្រប់គ្រាន់** - ជីអាសូត ហ្វូសហ្វាត និងប៉ូតាស់ជាអាហារចិញ្ចឹមដែលស្រូវ ត្រូវការស្រូបយកដើម្បីធំធាត់ ដូច្នេះគេត្រូវផ្តល់ទៅឱ្យដីនូវប្រភេទជីគីមី ដេ.អា.ប៉េ អ៊ុយរ៉េ និង ប៉ូតាស់ឱ្យបាន គ្រប់គ្រាន់តាមការណែនាំនៅពេល ដែលស្រូវត្រូវការ។

សុំបញ្ជាក់ថាជីគីមី ប្រើប្រាស់ត្រឹមត្រូវតាមការណែនាំគ្មានឥទ្ធិពលអ្វីប៉ះពាល់ដល់ដីអតិសុខុមប្រាណក្នុងដីឡើយ ។

- **ត្រូវបន្ថែមតិចតួចទៀតនូវប្រភេទកាល់ស្យូម និងម៉ាញ៉េស្យូម** - ជាមួយជីរួចដាក់ទៅក្នុងដីព្រោះវាមានឥទ្ធិពល ធ្វើឱ្យដើមស្រូវបង្កើនល្បឿនស្រូបយកសារធាតុចិញ្ចឹមពីដី។
- **បន្ថែមកំបោរដល់ដី** - ជាទូទៅដីស្រែវស្សានៅខេត្តតាកែវ ភាគច្រើនជាប្រភេទដីខ្សាច់ ល្បាយខ្សាច់ហើយ pH នៃដីជាមធ្យម ពី ៣.៥-៥.៥ ដូច្នេះកសិករចាំបាច់ត្រូវប្រើកំបោរសបាចទៅលើដីស្រែជាមធ្យមចំនួន ២00 គ.ក្រ ក្នុង១ហិកតា ដោយបាចពេល ភ្ជួររាស់ដីលើកទី១ ។

❖ **បន្ថែមដីដំបូក ដីល្បប់បាតត្រពាំង ឬ ដីឥដ្ឋ -** ក្នុងបំណងកែលំអដីសំបូរខ្សាច់ គេចាំបាច់ត្រូវបន្ថែមឱ្យដីនូវប្រភេទដីឥដ្ឋ ដីដំបូក ដីបាតត្រពាំងវាយឱ្យទៅជាដុំតូចៗ ហើយបាចទៅក្នុងស្រែជារៀងរាល់ឆ្នាំទៅតាមលទ្ធភាពជាក់ស្តែងដែលអាចធ្វើទៅបាន ។

## ពូជស្រូវក្រអូបផ្ការំដួល

ពូជផ្ការំដួលជាពូជស្រូវក្រអូបដែលបានធ្វើការរំដោះ និង ផ្សព្វផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៏កសិកម្មកម្ពុជានាឆ្នាំ១៩៩៩។ បច្ចុប្បន្នពូជផ្ការំដួលបាន និង កំពុងពេញនិយមក្នុងចំណោមប្រជាកសិករនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយពូជស្រូវនេះផ្តល់នូវទិន្នផលខ្ពស់គុណភាពអង្ករល្អមានភាពថ្លាវែងរលូន បាយទន់ឆ្ងាញ់ថែមទាំងមានក្លិនក្រអូបទៀតផងជាពិសេសទៅទៀត ជាពូជដែលមានប្រភេទអង្ករមានតំលៃខ្ពស់នៅលើទីផ្សារជាតិ និងអន្តរជាតិ។

### ❖ លក្ខណះពិសេសៗរបស់ពូជស្រូវផ្ការំដួល

ពូជផ្ការំដួលជាពូជស្រូវដែល “ប្រកាន់រដូវ ”មធ្យម។ វាចាប់ចេញផ្កាពីចុងខែតុលា អាស្រ័យទៅលើអាកាសធាតុ និងពេលវេលាដាំដុះ។ កំពស់ដើមរបស់ពូជផ្ការំដួលប្រែប្រួលពី ១០៧-១៧១ស,ម និងចំនួនដើមបែកគឺចាប់ពី ៥-១០ដើមក្នុងមួយគុម្ព “មួយគុម្ពស្ទូងមួយដើម” អាស្រ័យទៅតាមប្រភេទដី។ ចំនួនគ្រាប់ក្នុងមួយកួរ មានចាប់ពី ១១០-១៥០គ្រាប់ និងមានប្រវែងកួរ ១៨-២៨ស.ម។ រីឯទិន្នផលរបស់វាវិញគឺអាចទទួលបានចាប់ពី ៣,៥តោន ទៅ ៥,៥តោន ក្នុងផ្ទៃដី ១ ហិកតា។

### ❖ វិធីសាស្រ្តដាំដុះ

- ប្រើប្រាស់គ្រាប់ពូជដែលសុទ្ធល្អ និង មានអត្រាដំណុះខ្ពស់។
- បរិមាណ គ្រាប់ពូជ ចាំបាច់ ៣០-៥០គ.ក្រ ក្នុង១ហិកតា សំរាប់ស្រូវសន្ទូង និង ៨០-១២០គ.ក្រ ក្នុង ១ហិកតា សំរាប់ស្រូវពង្រួស។
- ទីសំណាបត្រូវធ្វើនៅជិត ប្រភពទឹកតែត្រូវឆ្ងាយពីម្លប់ព្រៃកន្លែងមានភ្លើងអគ្គីសនីដើម្បីចៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ។
- ផ្ទៃដីសំរាប់សាបគឺ ១គីឡូក្រាម ក្នុងផ្ទៃដី ១៥-២០ម៉ែត្រការ៉េ។
- ជាការល្អគួរស្ទូងសំណាបដែលមានអាយុ ២៥-៣០ថ្ងៃ ហើយក្នុង ១គុម្ព ២-៣ដើម។
- គួររៀបចំដីអោយបានល្អ មុនស្ទូង។ ការភ្ជួររាស់ គួរតែធ្វើអោយបាន ២-៣ សារជាការល្អ។

➢ បើសិនស្រែយើងអាចបញ្ចេញបញ្ចូលទឹកបាន ពេលស្រូវបែកគុម្ពត្រូវបញ្ចេញទឹកអោយអស់ពីក្នុងស្រែ ២-៤ថ្ងៃ រួចបញ្ចូលទឹកថ្មីវិញ។ នេះគឺដើម្បីធ្វើអោយស្រូវកាន់តែបែកគុម្ពល្អ។

# ពូជស្រូវក្រអូបសែនពិដោរ

សែនពិដោរ ជាពូជស្រូវស្រាល (អាយុកាលខ្លី) ក្រអូប និងមិនប្រកាន់រដូវ ដែលបានធ្វើការរំដោះ និងផ្សព្វផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជានា ខែ មេសា ឆ្នាំ ២០០២ នេះ។ បច្ចុប្បន្ន ពូជស្រូវសែនពិដោរបាន និង កំពុងរីកសាយភាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពូជស្រូវនេះផ្តល់នូវទិន្នផលខ្ពស់ មានក្លិនក្រអូប គុណភាពអង្ករល្អមានភាពថ្លាវែងរលូន និង បាយទន់ឆ្ងាញ់ពិសារទៀតផង។ ជាពិសេសទៅទៀត ជាពូជដែលមានប្រភេទអង្ករមានតំលៃខ្ពស់នៅលើទីផ្សារជាតិ និងអន្តរជាតិ។

## ❖ លក្ខណៈពិសេសៗរបស់ពូជស្រូវ សែនពិដោរ

ដោយសារពូជស្រូវសែនពិដោរ ជាពូជមិនប្រកាន់រដូវ ដូចនេះពូជនេះអាចចេញផ្កាបានគ្រប់ពេលវេលាដរាបណាល័ក្ខខណ្ឌដាំដុះអំណោយផល។ អាស្រ័យដោយហេតុផលខាងលើនេះទើបពូជសែនពិដោរអាចដាំដុះនៅដើមរដូវវស្សា (ដំណាំទីមួយនៃរដូវ ឬស្រូវដើមរដូវ) ក្នុងរដូវវស្សា (ដំណាំទីពីរនៃរដូវ) ចុងរដូវវស្សា ស្រូវប្រដេញទឹក (ដំណាំចន្លោះរដូវវស្សា និងរដូវប្រាំង) និង លក្ខខ័ណ្ឌប្រាំងស្រោចស្រព។ពូជស្រូវសែនពិដោរនេះមានអាយុកាលចាប់ពីថ្ងៃសាបរហូតដល់ថ្ងៃប្រមូលផលពី ១១០-១២០ថ្ងៃ ។ កំពស់ដើមរបស់ពូជសែនពិដោរប្រែប្រួលពី ៩៥-១១០ស.ម និងចំនួនដើមបែកគឺចាប់ពី ៥-២០ដើមក្នុងមួយគុម្ព ។ ចំនួនគ្រាប់ក្នុងមួយកួរមានចាប់ពី ១១០-១៧០គ្រាប់ និងមានប្រវែងកួរ២០-៣០ស.ម។ រីឯទិន្នផលរបស់វាវិញគឺអាចទទួលបានចាប់ពី ៣,៥ តោន ទៅ ៥,៥តោនក្នុងផ្ទៃដីមួយហិកតា។

## ❖ វិធីសាស្ត្រដាំដុះ

- ប្រើប្រាស់គ្រាប់ពូជដែលសុទ្ធល្អ និង មានអត្រាដំណុះខ្ពស់។
- កំរិតបរិមាណគ្រាប់ពូជចាំបាច់ ៣០-៥០គ.ក្រ ក្នុងមួយហិកតាសំរាប់ស្រូវសន្ទូង និង ៨០-១២ ០គ.ក្រ ក្នុងមួយហិកតា សំរាប់ស្រូវពង្រួស។
- ទីសំណាប ត្រូវធ្វើនៅជិតប្រភពទឹក តែត្រូវឆ្ងាយពីម្លប់ឈើ ឬ កន្លែងមានភ្លើងអគ្គីសនីដើម្បីចៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ។
- ផ្ទៃដីសំរាប់សាបគឺ ១គ.ក្រ ក្នុងផ្ទៃដី ១៥-២០ម៉ែត្រការ៉េ។
- ជាការល្អគួរស្ទូងសំណាបដែលមានអាយុ ២០-២៥ ថ្ងៃ ហើយក្នុង ១គុម្ព ២-៣ ដើមក្នុងចន្លោះ ២០ស.ម។
- គួររៀបចំដីអោយបានល្អមុនស្ទូង។ ការភ្ជួររាស់ គួរតែធ្វើអោយបាន២-៣សារជាការល្អ។

➢ បើសិនស្រែយើងអាចបញ្ចេញបញ្ចូលទឹកបាន ពេលស្រូវបែកគុម្ពត្រូវបញ្ចេញទឹកអោយអស់ពីក្នុងស្រែក្នុងរយៈពេលពី ២-៤ថ្ងៃ រួចទើបបញ្ចូលទឹកឡើងវិញដើម្បីធ្វើអោយស្រូវកាន់តែបែកគុម្ពល្អ។

## ពូជស្រូវកណ្តាល ខា១

ពូជស្រូវ “ខា ១” ជាពូជស្រូវកណ្តាលដែលបានធ្វើការរំដោះ និងផ្សព្វផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជានាឆ្នាំ ១៩៩៥។ បច្ចុប្បន្នពូជស្រូវកណ្តាល “ខា ១” បាននឹងកំពុងពេញនិយមក្នុងចំណោមប្រជាកសិករនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយពូជស្រូវនេះផ្តល់នូវទិន្នផលខ្ពស់។

### លក្ខណៈពិសេសៗរបស់ពូជស្រូវ“ខា១”

ពូជស្រូវកណ្តាល “ខា ១” ជាពូជស្រូវប្រកាន់រដូវមធ្យម។ វាចាប់ចេញផ្កាក្នុងកំឡុងថ្ងៃទី ០២-០៩ខែវិច្ឆិកាអាស្រ័យទៅលើអាកាសធាតុ និងពេលវេលាដាំដុះ។ កំពស់ដើមរបស់ ពូជស្រូវ“ខា ១” ប្រែប្រួលពី ១៣០-១៨០ស.ម និង ចំនួនដើមបែកផ្តល់ផល គឺចាប់ពី៨-១០ដើមក្នុងមួយគុម្ព អាស្រ័យ ទៅតាមប្រភេទដី។ ចំនួនគ្រាប់ក្នុងមួយកួរមានចាប់ពី ១១០-១៥០គ្រាប់ និងមានប្រវែងកួរ ២០-២៥ស.ម។ រីឯទិន្នផល របស់វាវិញ គឺអាចទទួលបានចាប់ពី ២,៥តោន ទៅ ៤,០តោន ក្នុងផ្ទៃដី ១ហិកតា។ ពូជស្រូវ “ខា ១” មិនធន់ទៅនឹងមមាចត្នោតទេ។

### វិធីសាស្ត្រដាំដុះ

សម្រាប់ស្រូវសន្ទូង ចំពោះតំបន់ដែលងាយរងគ្រោះរាំងស្ងួត និងទឹកជំនន់បរិមាណគ្រាប់ពូជដែលប្រើប្រាស់ គឺពី ៦០-៨០ គីឡូក្រាមក្នុងមួយហិកតា។ ចំពោះតំបន់ដែលគ្រប់គ្រងទឹកបានបរិមាណគ្រាប់ពូជដែលប្រើប្រាស់គឺពី ៣០-៤០គីឡូក្រាមក្នុងមួយហិកតា។ ក្នុងករណីដែលគ្រាប់ពូជសុទ្ធ និង មានសុខភាពល្អ ព្រមទាំងគ្រប់គ្រងទឹកបាន និង ថែទាំបានល្អបរិមាណគ្រាប់ពូជដែលត្រូវការក្នុងមួយហិកតាគឺ ពី ១៥-២០គីឡូក្រាម។ ដើម្បីឱ្យសំណាបដុះលូតលាស់ធំធាត់ល្អ គេត្រូវសាបគ្រាប់ពូជមួយគីឡូក្រាមលើផ្ទៃដីថ្នាល ២០ម៉ែត្រការ៉េ។ ទីសំណាបត្រូវធ្វើនៅជិតប្រភពទឹក តែត្រូវឆ្ងាយពីម្លប់ព្រៃ ឬកន្លែងមានភ្លើងអគ្គិសនីដើម្បីជៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ។ ជាការល្អគួរស្ទូងសំណាបដែលមានអាយុ ២៥-៣០ថ្ងៃ ហើយក្នុងមួយគុម្ពចំនួន ២-៣ដើម។ សម្រាប់ស្រូវពង្រួស ចំពោះតំបន់ដែលងាយរងគ្រោះរាំងស្ងួតនិងទឹកជំនន់ បរិមាណគ្រាប់ពូជដែលប្រើប្រាស់គឺពី ១០០-១៥០គីឡូក្រាមក្នុងមួយហិកតា។ ចំពោះតំបន់ដែលគ្រប់គ្រងទឹកបាន និងគ្រាប់ពូជសុទ្ធល្អបរិមាណគ្រាប់ពូជដែលប្រើប្រាស់គឺ ពី៧០-៨០គក្រក្នុងមួយហិកតា។ គួររៀបចំដីឱ្យបានល្អ និងរាបស្មើមុនស្ទូងឬព្រួស។

ការភ្ជួររាស់គួរតែធ្វើឱ្យបាន ២-៣សារជាការល្អប្រសើរ។ បើសិនស្រែអាចបញ្ចេញបញ្ចូលទឹកបាន បន្ទាប់ពីស្ទូងឬព្រួសបាន ២០ថ្ងៃអាចបញ្ចេញទឹកឱ្យអស់ពីក្នុងស្រែ ២-៤ថ្ងៃ រួចបញ្ចូលទឹកថ្មីវិញ។ ធ្វើរបៀបនេះគឺដើម្បីធ្វើឱ្យស្រូវកាន់តែបែកគុម្ពល្អ។ ប៉ុន្តែពេលស្រូវបែកគុម្ពអតិបរិមា គួរបង្ហូរទឹករយៈពេលមួយអាទិត្យ ដើម្បីកុំឱ្យស្រូវដុះខ្នែងមកច្រើនទៀត។

# ពូជស្រូវស្រាលអ៊ីអ៊ែរ ៦៦

"អ៊ីអ៊ែរ ៦៦" ជាពូជស្រូវស្រាលមិនប្រកាន់រដូវដែលបានធ្វើការរំដោះ និងផ្សព្វផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៏កសិកម្មកម្ពុជានាឆ្នាំ ១៩៩០។ បច្ចុប្បន្នពូជស្រូវ "អ៊ីអ៊ែរ ៦៦" បាននិងកំពុងរីកសាយភាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយពូជស្រូវនេះផ្តល់នូវទិន្នផលខ្ពស់ គុណភាពអង្ករល្អ និងមានអាយុកាលខ្លី។

## លក្ខណៈពិសេសៗរបស់ពូជស្រូវ "អ៊ីអ៊ែរ ៦៦"

ពូជស្រូវ "អ៊ីអ៊ែរ ៦៦" ជាពូជស្រូវដែលមិនប្រកាន់រដូវ និងអាចចេញផ្កាគ្រប់ពេលវេលាដរាបណាល័ក្ខខណ្ឌដាំដុះអនុគ្រោះដល់ការលូតលាស់របស់វា។ អាស្រ័យដោយហេតុផលខាងលើនេះទើបពូជនេះអាចដាំដុះនៅដើមរដូវវស្សា(ដំណាំទីមួយនៃរដូវឬ ស្រូវដើមរដូវ) ក្នុងរដូវវស្សា (ដំណាំទីពីរនៃរដូវ) ចុងរដូវវស្សា ស្រូវប្រដេញទឹក (ដំណាំចន្លោះរដូវវស្សា និង រដូវប្រាំង) និងលក្ខខ័ណ្ឌប្រាំងស្រោចស្រព។ ពូជស្រូវ "អ៊ីអ៊ែរ ៦៦" នេះមានអាយុកាលពី ១០០-១១៥ថ្ងៃ គឺចាប់ពីថ្ងៃសាបរហូតដល់ថ្ងៃប្រមូលផល។ កំពស់ដើមរបស់ពូជ "អ៊ីអ៊ែរ ៦៦" ប្រែប្រួលពី ៨០-១១៨ស.ម និងចំនួនដើមបែកគឺចាប់ពី ១២-១៨ ដើមក្នុងមួយគុម្ពអាស្រ័យទៅតាមប្រភេទដី។ ចំនួនគ្រាប់ក្នុងមួយកួរមានចាប់ពី ៩៥-១០២គ្រាប់និងមានប្រវែងកួរ ២៥-២៦ ស.ម។ រីឯទិន្នផលរបស់វាវិញគឺអាចទទួលបានចាប់ពី ៤,០តោន ទៅ ៦,៥តោន ក្នុងផ្ទៃដី ១ហិកតា។

## វិធីសាស្ត្រដាំដុះ




-ប្រើប្រាស់គ្រាប់ពូជដែលសុទ្ធល្អនិងមានអត្រាដំណុះខ្ពស់។

-កំរិតបរិមាណគ្រាប់ពូជចាំបាច់ ៣០-៥០គ.ក្រ ក្នុង១ ហិកតា សំរាប់ស្រូវសន្ទូង និង ៨០-១២០គ.ក្រ ក្នុង១ហិកតា សំរាប់ស្រូវពង្រួស។

-ទីសំណាប ត្រូវធ្វើនៅជិតប្រភពទឹក តែត្រូវឆ្ងាយពីម្លប់ព្រៃ ឬកន្លែងមានភ្លើងអគ្គិសនី ដើម្បីជៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ។

-ផ្ទៃដីសំរាប់សាបគឺ ១គីឡូក្រាមគ្រាប់ពូជក្នុងផ្ទៃដី១៥-២០ ម៉ែត្រការ៉េ។

-ជាការល្អគួរស្ទូងសំណាបដែលមានអាយុ ២០-២៥ថ្ងៃ ហើយក្នុង ១គុម្ព ២-៣ ដើមក្នុងចន្លោះ ២០ គុណ ២០ស.ម។

-គួររៀបចំដីអោយបានល្អមុនស្ទូង។ ការភ្ជួររាស់ គួរតែធ្វើអោយបាន ២-៣ សារ ជាការល្អ។

- បើសិនស្រែយើងអាចបញ្ចេញបញ្ចូលទឹកបាន ពេលស្រូវបែកគុម្ពត្រូវបញ្ចេញទឹកអោយអស់ពីក្នុងស្រែ ២-៤ថ្ងៃ រួចបញ្ចូលទឹកថ្មីវិញ។ នេះគឺដើម្បីធ្វើអោយស្រូវកាន់តែបែកគុម្ពល្អ។

# ប្រពលវប្បកម្មដំណាំស្រូវ

## សេចក្តីផ្តើម

ប្រពលវប្បកម្មដំណាំស្រូវ គឺជាការអនុវត្តត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសគ្រប់ដំណាក់កាលលូតលាស់របស់ស្រូវ ដើម្បីទទួលបានទិន្នផលខ្ពស់ ប្រាក់ចំណេញច្រើន និងរក្សាបាននូវប្រពន្ធ័បរិស្ថានមានស្ថេរភាព។

**បច្ចេកទេសនៃការអនុវត្តប្រពលវប្បកម្មដំណាំស្រូវ**

បទដ្ឋានបច្ចេកទេសនៃការអនុវត្តប្រពលវប្បកម្មដំណាំស្រូវមាន:

-ត្រូវសាបឱ្យបានសំណាបល្អ សំរាប់ស្ទូងក្នុងស្រែ

-រៀបចំដីសំរាប់ស្ទូងឱ្យបានល្អដើម្បីឱ្យសន្ទូងងាយស្រួលលូតលាស់បានល្អ

-ដកសំណាបនិងស្ទូងបានតាមបច្ចេកទេស

-ប្រើប្រាស់ជីឱ្យបានគ្រប់គ្រាន់ តាមតំរូវការរបស់ស្រូវ

-គ្រប់គ្រងទឹកតាមដំណាក់កាលលូតលាស់របស់ស្រូវ

-កំចាត់ស្មៅចង្រៃនិងសត្វល្អិតចង្រៃបានទាន់ពេលវេលា

-អនុវត្តត្រឹមត្រូវតាមបច្ចេកទេសនៃការប្រមូលផល

## ១. ការសាបសំណាបឱ្យបានល្អសំរាប់ស្ទូង

សំណាបល្អពេលដកយកទៅស្ទូង សន្ទូងនឹងលូតលាស់បានឆាប់រហ័ស ដូច្នេះកសិករត្រូវរៀបចំសាប និងថែរក្សាសំណាបឱ្យបានល្អសំរាប់ដកយកទៅស្ទូង។

**សំណាបល្អមានលក្ខណះដូចម្តេច?**

.មានស្រទបស្លឹកខ្ចី

.មានដើមដងរឹងមាំ ស្លឹកមិនសំយ៉ាកចុះ

.ដើមសំណាបមានការលូតលាស់ស្មើគ្នា ទំហំដើមដងស្មើគ្នា

.សំណាបមានទំងន់ធ្ងន់និងមានឬសច្រើនគ្មានស្នាមសត្វល្អិត និងជំងឺបំផ្លាញ



សំណាបមិនល្អ សំណាបល្អ

**ធ្វើដូចម្តេចដើម្បីសាបសំណាប់បានល្អ?**

**ជ្រើសរើសគ្រាប់ពូជឱ្យបានល្អ**

គ្រាប់ពូជល្អ តែងនាំមកនូវដំណុះគ្រាប់ស្មើគ្នា ការលូតលាស់ដើមស្រូវស្មើល្អ និងធ្វើឱ្យដើមសំណាបមានដើមដងស្លឹកមានកំលាំងខ្លាំងនិងមានឬសដុះច្រើន។ គ្រាប់ពូជល្អ មានទំហំប៉ុនគ្នា គ្មានសំដី ឬគ្រាប់ស្មៀតគ្មានគ្រាប់ស្មៅលាយឡំគ្មានស្លាកស្នាមជាំដោយសត្វល្អិតនិងជំងឺបំផ្លាញនិងមានសំណើមស្ងួតល្អ ១៣-១៤ ភាគរយ។

សំរាប់ផ្ទៃដី ១ហ.តត្រូវប្រើគ្រាប់ពូជល្អចំនួន ៣០-៣៥គក្រ ។

**ការបណ្តុះគ្រាប់**

-មុនយកគ្រាប់ពូជទៅសាបជាការល្អត្រូវសាកដំណុះគ្រាប់ជាមុន  គ្រាប់ពូជល្អត្រូវមាន ដំណុះច្រើនជាង៩០ភាគរយ ។

-ត្រូវហាលគ្រាប់ស្រូវឱ្យបានន ២-៣ម៉ោង រួចចាក់ត្រាំក្នុងធុងឬពាងរយៈពេល ២៤ម៉ោង

-លាងគ្រាប់ស្រូវរួចស្រង់សំរ៉ស់ទឹកហើយផ្អាប់ដោយចាក់ធារលើកន្ទេលឬសំបកបាវសើមនិងគ្របដោយសំបកបាវ សើមរយះពេល ៣៦ម៉ោង ។ ត្រូវឧស្សាហ៍ពិនិត្យមើលគ្រាប់ស្រូវ បើគ្រាប់ស្រូវស្ងួតពេក ត្រូវប្រោះទឹកបន្ថែម ។

**ការរៀបចំថ្នាលសំណាប**

-ភ្ជួរឱ្យបាន ២ទៅ៣លើកទាល់តែស្មៅ ទើបរាស់រណ្តំ

-ដាក់ជីលាមកសត្វចំនួន ៥រទេះ លើផ្ទៃដី ១០០ម² រាយឱ្យស្មើ បញ្ចូលទឹករួចភ្ជួរនិងគៀររាស់រហូតទាល់តែដីរាបស្មើ

-ឆ្វតចង្អូរ ចន្លោះចង្អូរពី ២ម -២,៥០ម បង្ហូរទឹកចេញឱ្យអស់និងតំរឹមជើងចង្អូរឱ្យបានត្រង់ស្អាតល្អ

-ដើម្បីងាយស្រួលដក គេបន្ថែមផេះអង្កាមរោយលើរងថ្នាលសំណាប រួចទើបសាបគ្រាប់ពូជចំពោះប្រភេទដីកណ្តេង គេប្រើផេះអង្កាមច្រើនជាងដីខ្សាច់ផេះអង្កាមត្រូវត្រាំទឹក១យប់ហើយហាលសំដិលឱ្យស្រោះទឹកទើបយកទៅរាយលើថ្នាល ។

**ការសាបគ្រាប់ពូជ**

-ផ្ទៃដីសំរាប់សាប ១ គក្រ ពូជត្រូវសាបលើផ្ទៃដីទំហំ ២០ម² សំរាប់ស្ទូងលើផ្ទៃដី ១ហ.ត ថ្នាលសាបត្រូវមានទំហំ ៦០០ម²

-ដើម្បីសាបបានស្មើ គេដោតបង្គោលឬស្សី ចំណាំលើផ្ទៃដី ២០ម²ហើយសាបម្តងពូជ ១គក្រ

-គ្រាប់ពូជដែលល្អមសមស្របសំរាប់សាប គឺប្រេះមាត់ចាបនិងពកពន្លកបន្តិច ។

**ការថែររក្សាសំណាប**

-ក្រោយសាបពី ៣-៥ ថ្ងៃត្រូវរក្សាថ្នាលសំណាបកុំឱ្យមានទឹកដក់

-៥ថ្ងៃក្រោយត្រូវបញ្ចូលទឹកពី ២-៣ ស.ម នៅក្នុងថ្នាលនិង ៥ស.ម នៅរយះពេល១២ថ្ងៃក្រោយ និង១០ស.ម នៅរយះពេល២០ថ្ងៃ ក្រោយ កាលណាលទឹកជ្រៅពេកធ្វើឱ្យសំណាបមានស្រទបស្លឹកវែង ដើមសំណាបតូចឆ្មារទន់

-ពិនិត្យមើលការលូតលាស់របស់សំណាប  បើលូតលាស់ល្អគេពុំចាំបាច់ថែមជីទេ តែបើលូតលាស់មិនសូវល្អ ១០ថ្ងៃ ក្រោយសាបគេត្រូវបាចជី អ៊ុយរ៉េបន្ថែមចំនួន ១គក្រ សំរាប់លើផ្ទៃដីថ្នាលសំណាប ១០០ ម² ។

-ត្រូវឧស្សាហ៍ពិនិត្យមើលសំណាបករណីមានសត្វល្អិតបំផ្លាញដូចជាទ្រីព និងមមាចត្នោតត្រូវមានវិធានការកំចាត់ ភ្លាម ។

## ២. ការរៀបចំដីសំរាប់ស្ទូងឱ្យបានត្រឹមត្រូវល្អ

**ការរៀបចំដីបានល្អគឺ**

-ដីស្រទាប់លើជំរៅពី ១៥ស.ម-១៨ស.ម ធូរ មានខ្យល់ចេញចូលស្រួលដែលបង្ករលទ្ធភាពឱ្យប្រពន្ធ័ឫសលូតលាស់បានល្អ។

-ស្មៅនិងកាកសំណល់រុក្ខជាតិផ្សេងៗបានកប់ចូលទៅក្នុងដី ហើយរលួយទៅជាជីរាប់ដំណាំស្រូវ

-ជីលាមកសត្វនិងជីគីមីដែលបានដាក់ចូលទៅក្នុងដីសំរាប់ទ្រាប់បាត ត្រូវបានលាយច្របល់បង្កប់ទៅក្នុងដីដែលអាចកាត់បន្ថយការរំភាយអាសូតទៅក្នុងខ្យល់។

-ដីស្រែត្រូវគៀរពង្រាបបានស្មើ ដែលធ្វើឱ្យមានការងាយស្រួលក្នុងការគ្រប់គ្រងទឹក និងប្រើប្រាស់ទឹកអស់បរិមាណតិច។

**ផលប្រយោជន៍នៃការរៀបចំដីបានល្អ**

-បន្ថយបរិមាណស្មៅដុះតិចជាងធម្មតា ៤០ភាគរយ

-ប្រើប្រាស់ទឹកតិច និងងាយស្រួលក្នុងការកំរឹតកំពស់ទឹកក្នុងស្រែ

-ស្រូវលូតលាស់និងទុំដំណាលគ្នានិងមានផ្លែនិងទំហំគ្រាប់ស្មើគ្នា

-ទិន្នផលស្រូវកើនខ្ពស់ជាងប្រមាណ ៣០ភាគរយ

**ការរៀបចំដីសំរាប់ស្ទូងឱ្យបានល្អ**

-លើកភ្លឺស្រែឱ្យបានរឹងមាំ ជំរះស្មៅតាមភ្លឺស្រែលប់រន្ធក្តាមកុំឱ្យទឹកហូរចេញចូល ការងារនេះគួរធ្វើនៅពេលដាស់ដីលើកទី១

-ធ្វើការភ្ជួរដាស់ដីលើកទី១១ នៅពេលដែលដីសើមអាចភ្ជួរមុតបាន ឬពេល ដែលដីស្រែមានទឹកដក់គ្រប់គ្រាន់

-ភ្ជួរដីលើកទី ២ ពី ១០-១៥ថ្ងៃ តែបើដីស្រែនៅមានស្មៅច្រើន ត្រូវភ្ជួរដាស់ដី និងរាស់រណ្តំជាលើកទី២ ក្នុងករណីមិនសូវមានស្មៅការភ្ជួរលើកទី ២នេះអាចសំរាប់ស្ទូងបានដោយមុនភ្ជួរគេបាចជីលាមកសត្វ និងជីគីមីសំរាប់ទ្រាប់បាតរាយឱ្យស្មើលើដីស្រែ រួចភ្ជួរ និងគៀររាស់ពង្រាបដីឱ្យស្មើ និងធ្វើឱ្យជីលាមកសត្វនិងជីគីមីដែលបាចច្របល់សព្វបង្កប់ទៅក្នុងដី។

-ករណីយដីខ្ពស់ទាបច្រើនការគៀរពង្រាបត្រូវប្រើគោយន្តទើបអាចធ្វើទៅបានល្អ ហើយនៅកន្លែងខ្ពស់ដែលត្រូវគៀរចេញទៅកន្លែងទាបនោះ គេត្រូវបន្ថែមជីលាមកសត្វនិងជីគីមីម្តងទៀតរួចធ្វើការភ្ជួររាស់កន្លែងនោះម្តងទៀត។

## ៣. ការដកសំណាបនិងស្ទូង

**ការដកសំណាប**

-ពេលដកសំណាប ថ្នាលសំណាបត្រូវមានទឹកគ្រប់គ្រាន់

-អាយុសំណាបដែលសមស្របសំរាប់ដកយកទៅស្ទូងគឺ សំណាបពូជស្រូវសែនពិដោរអាយុពី ២០-២៥ថ្ងៃ ខា១ និងផ្ការំដួលអាយុពី២៥-៣០ថ្ងៃ។

-ដកថ្នមៗមិនឱ្យបាក់ដើមនិងដាច់ឬស រួចដាក់ក្នុងកាធុនឬបង្គីរ (មិនបោកមិនចងរឹត) រួចដញ្ជូនយកទៅស្ទូងភ្លាម

**ការស្ទូង**

-ស្រែដែលស្ទូងត្រូវមានទឹកគ្រប់គ្រាន់ តែមិនជ្រៅពេកទេ

-សំណាបដែលល្អមានស្លឹកខ្លីគេពុំចាំបាច់កាត់ស្លឹកទេ តែបើស្លឹកវែងពេកចាំបាច់ត្រូវកាត់ស្លឹកចេញ

-ត្រូវស្ទូងឱ្យដើមបានឈរត្រង់ល្អនិងស្ទូង២-៣ដើមក្នុង១គុម្ព ជំរៅពី ២-៣ស.ម ការស្ទូងជ្រៅពេកតែងពន្យាការបែកគុម្ព ។

-ស្ទូងជាជួរឬមុំចង្រ្កានក៏បាន តែត្រូវរក្សាចន្លោះគុម្ព ២០ស.ម គុណ ២០ស.ម បើស្ទូងស្មើល្អគេនឹងទទួលបានសន្ទូងចំនួន២៥០.០០០គុម្ព/ហ.ត

-ក្នុងរាល់ចន្លោះសន្ទូង ១០ម-១៥ម គេរក្សាទុកចង្អូរ ១ ដើម្បីជាផ្លូវសំរាប់ចុះពិនិត្យសត្វល្អិត បាចជី និងបោចស្មៅ

## ៤. ការប្រើប្រាស់ជីលើដំណាំស្រូវ

ជីជាសារធាតុចិញ្ចឹមរបស់ដំនាំស្រូវ ដូច្នេះដើម្បីលូតលាស់បាននិងផ្តល់ផ្លែផ្កាបានល្អស្រូវត្រូវការសារធាតុចិញ្ចឹមគ្រប់គ្រាន់ទៅតាមតំរូវការរបស់វា ។ សារធាតុសំខាន់គឺ អាហ្សូត ហ្វូស្វាត និងប៉ូតាស្យូម ។

ជីដែលត្រូវប្រើសំរាប់ដំណាំស្រូវ គឺជីធម្មជាតិ និងជីគីមី ។ ការប្រើប្រាស់ជីធម្មជាតិតែមួយប្រភេទ មិនអាចផ្តល់សារធាតុចិញ្ចឹមគ្រប់គ្រាន់ឱ្យស្រូវបានទេ ផ្ទុយទៅវិញការប្រើជីគីមីតែមួយប្រភេទ វាមានលទ្ធភាពផ្តល់សារធាតុចិញ្ចឹមបានច្រើនឱ្យស្រូវ ប៉ុន្តែវាធ្វើឱ្យដីបាត់បង់លក្ខណះរូបនិងលក្ខណះជីវសាស្រ្ត។

### ៤.១ ជីធម្មជាតិនិងជីកំប៉ុស្ត

ជីធម្មជាតិនិងជីកំប៉ុស្តវាមានគុណប្រយោជន៍ប្រើប្រាស់សំខាន់ក្នុងគោលបំណងសំរាប់កែលំអរ លក្ខណះរូបនិងលក្ខណះជីវសាស្រ្តរបស់ដី តែចំពោះជីជាតិវិញ វាមានកំរិតតិច ដូចេះគេត្រូវបើវាក្នុងបរិមាណច្រើន ។

**-ការធ្វើជីកំប៉ុស្តិ៍**



***វត្ថុធាតុ:*** លាមកសត្វ (គោ ក្របី សេះ ដំរី ជ្រូក មាន់ ទា...) គ្រប់ប្រភេទ, កាកសំណល់រុក្ខជាតិ ដូចជា ដើមដង មែក ធាង រុក្ខជាតិបៃតង ស្មៅ ចំបើង ផេះ និង កាកសំណល់ផ្ទះបាយ ។

***ទំហំរណ្តៅជី :*** បណ្តោយ ៣មគុណ ទទឹង ២ម គុណកំពស់ ០,៥ -១ម សំរាប់ គោ១នឹម។

រោងជីកំប៉ុស្តិ៍

**-វត្ថុធាតុដើមសំរាប់ធ្វើជីប៉ុស្តិ៍**

- លាមកសត្វៈគោ ក្របី មាន់ទា ជ្រូក
- ផេះ កាកសំណល់ចំណីសត្វ, កាកសំណល់ផ្ទះសំបែង និងស្រែចំការ
- សំរាម ស្លឹកឈើ និងកំទេចកំទីរុក្ខជាតិផ្សេងៗ ជុំវិញផ្ទះសំបែង និងស្រែចំការ

ចំពោះវត្ថុធាតុដែលបានប្រមូលរៀបចំជាមុនហើយនោះ គេត្រូវរៀបចំជាស្រទាប់ៗ ដោយដាក់ដើមដង មែក ធាង ស្លឹកឈើ ឬស្មៅ ឬកូនរុក្ខជាតិតូចៗ ដែលកាប់ចិញ្រ្ចាំ ឬវត្ថុធាតុបណ្តុះផ្សិត ឬកាកសំណល់ពីកសិដ្ឋានពីទ្រុងសត្វ និង ពីផ្ទះបាយ នៅបាតរណ្តៅកំរាស់ ប្រមាណ ៣០ស.ម រួចរាយលាមកសត្វកំរាស់ ១០ស.ម ពីលើរួចរាយផេះ ឬអង្កាម ឬ កំបោរកំរាស់ ប្រមាណ ៥ស.ម ហើយធ្វើរបៀប នេះរហូតដល់ពេញរណ្តៅទើប ស្រោចទឹកម៉ូត ឬទឹកពីលើ ព្រមទាំងគ្របដោយស្លឹកឈើ ឬ ធាងដូងដើម្បីរក្សាកំដៅ និងសំណើម ។

ចំពោះករណីសន្សំបន្តិចម្តងៗ គេត្រូវប្រមូលសារធាតុទាំងនោះដាក់ក្នុងរណ្តៅជីទោះបីជាសារធាតុអ្វីក៏ដោយ ប៉ុន្តែគេ ត្រូវរើសសារធាតុមិនរលួយចេញឱ្យអស់ ដូចជាសំបកកំប៉ុង ថង់ប្លាស្ទិក ដែក និងអំបែងកែវ ។ល។ រណ្តៅជីត្រូវស្រោចទឹក ជាប្រចាំដើម្បីអោយជីឆាប់រលួយ ។ បើជីលាមកគោមានច្រើននៅក្នុងជីកំប៉ុស្ត ជីអាចរលួយឆាប់គឺ ក្នុងរយៈពេល ៣-៤ខែ អាចយកមកប្រើបាន ។

ជីលាមកសត្វផ្តល់សារធាតុ អាសូតសំរាប់បង្កើនយ៉ាងរហ័សនូវសារធាតុចិញ្ចឹមក្នុងជីកំប៉ុស្ត ។ គោធំមួយក្បាលអាច ផ្តល់លាមកពី ១០-១២គក្រ ក្នុងមួយថ្ងៃ និងប្រហែល **<u>៤តានក្នុងមួយឆ្នាំ។</u>** ដូច្នេះគោធំមួយនឹមអាចផ្តល់ជីកំប៉ុស្តបាន **<u>១២ តោនក្នុងមួយឆ្នាំ</u>** ។ ផេះ ឬកំបោរផូស្វាតជួយបន្ថែមសារធាតុរ៉ែដល់ជីកំប៉ុស្តឱ្យឆាប់រលួយបានល្អ ព្រមទាំងជួយបន្ថយជាតិ អាស៊ីត និងបង្កលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់ទៀតផងពិសេសលេប្រភេទដីជូ។

**សមាសធាតុគីមីដែលមាននៅក្នុងជីកំប៉ុស្តិ៍ដែលមានគុណភាពខ្ពស់**

| សារធាតុបន្សំមានក្នុងជីកំប៉ុស្តដែលមានគុណភាពល្អ | | | |
|---|---|---|---|
| អាសូត | ១,៣៥% | ម៉ាញ៉េស្យូម | ០,៨៨% |
| ផូស្វ័រ | ១,៧៥% | សារធាតុខនិជ | ៣៣% |
| ប៉ូតាស្យូម | ២,២៦% | | |

**-របៀបប្រើប្រាស់ជីកំប៉ុស្តិ៍**

ជីកំប៉ុស្តដែលយើងយកទៅប្រើត្រូវធានាថាវាបានពុកផុយ ឬកាច់អស់គ្មានកំដៅគ្មានក្លិនអាក្រក់។ ប្រសិនបើវាមិន ទាន់កាច់អស់នៅពេលយកវាទៅប្រើ វានឹងបញ្ចេញកំដៅអាចប៉ះពាល់ដល់ឬសស្រូវ (ធ្វើឱ្យដំណាំរលួយ)។

គេប្រើជាជីទ្រាប់បាតមុនពេលភ្ជួររាស់សំរាប់ស្ទូងដោយប្រើចំនួនពី ៥-១០តោន/ហ.ត ។

## ៤.២ ជីគីមី

ជីគីមីត្រូវផលិតដោយរោងចក្រឧស្សាហកម្មដោយសំយោគសិប្បនិម្មិតប្រមូលផ្តុំនៃអាហារចិញ្ចឹមដូចជា អាហ្សូត ហ្វូស្វាត និងប៉ូតាស្យូម ដែលរុក្ខជាតិត្រូវការជាងគេ ចេញពីបណ្តាសារធាតុដែលមាននៅក្នុងធម្មជាតិ ។

ជីគីមីត្រូវបានផ្សំជាប្រភេទជីទោល និងជីសមាស

**ក. ជីទោល** ដែលប្រើប្រាស់បច្ចុប្បន្នមាន

**-ជីអ៊ុយរ៉េ** ដែលក្នុង១០០គក្រ មានធាតុអាហ្សូតសុទ្ធចំនួន៤៦គក្រ ហើយនៅលើសំបកបាវគេមាន សរសេរលេខ **៤៦.០.០** មានន័យថា

- ៤៦ ជាចំនួនធាតុអាសូត ក្នុងជី ១០០គក្រ
- ០ ជាចំនួនធាតុហ្វូស្វាត ក្នុងជី ១០០គក្រ
- ០ ជាចំនួនធាតុប៉ូតាស្យូម ក្នុងជី ១០០គក្រ

**-ជីប៉ូតាស្យូមក្លរ** ដែលក្នុង១០០គក្រមានធាតុប៉ូតាស្យូមសុទ្ធចំនួន ៦០គក្រហើយនៅលើសំបកបាវគេមាន សរសេរលេខ **០.០.៦០** មានន័យថា

- ០ ជាចំនួនធាតុអាសុត ក្នុងជី ១០០គក្រ
- ០ ជាចំនួនធាតុហ្វូស្វាត ក្នុងជី ១០០គក្រ
- ៦០ ជាចំនួនធាតប៉ូតាស្យូម អាសូត ក្នុងជី ១០០គក្រ

**ខ. ជីសមាសដែលផ្សំសារធាតុ ២ មុខ** ដែលប្រើប្រាស់បច្ចុប្បន្នមាន

**-ជីដេអាប៉េ** ដែលក្នុង១០០គក្រមានធាតុអាហ្សូតសុទ្ធចំនួន១៨គក្រ និងធាតុហ្វូស្វាតចំនួន ៤៦គក្រ នៅលើសំបកបាវគេមានសរសេរលេខ **១៨.៤៦.០** មានន័យថា



- ១៨ ជាចំនួនធាតុុអាសុត ក្នុងជី ១០០គក្រ
- ៤៦ ជាចំនួនធាតុហ្វូស្វាត ក្នុងជី ១០០គក្រ
- ០ ជាចំនួនធាត ប៉ូតាស្យូម ុអាសូត ក្នុងជី ១០០គក្រ

**-ជី ១៦.២០.០** ដែលក្នុង១០០គក្រមានធាតុអាហ្សូតសុទ្ធចំនួន១៦គក្រ និងធាតុហ្វូស្វាត ចំនួន២០គក្រ នៅលើសំបកបាវគេមានសរសេរលេខ **១៦.២០.០** មានន័យដូចខាងលើ ។

**គ.ជីសមាសដែលផ្សំសារធាតុ ៣ មុខ និង ៤មុខ** ដែលប្រើប្រាសបច្ចុប្បន្នមាន

-ជី ១៥.១៥.១៥ ជី ១៦.១៦.៨.១៣

➢ **ការប្រើប្រាសជីគីមី លើដំណាំស្រូវ**

ការប្រើប្រាស់ជីសមស្របតាមកំរិតណែនាំ នឹងមិនបណ្តាលអោយមានការថយចុះ ឬបាត់បង់ក្លិន ឬ គុណភាពដ៏ទៃទៀតឡើយ ។ ការប្រើប្រាស់ជីអាស្រ័យទៅតាមប្រភេទដី ។



*ក្រុមដីបាកាន*



*ក្រុមដីប្រទះឡាង*



*ក្រុមដីព្រៃខ្មែរ*

**-ដីក្រុមប្រទះឡាង និងដីព្រៃខ្មែរ** ប្រើជីអ៊ុយរ៉េ ចំនួន ៧៧គក្រ ជីដេអាប៉េ ៨៧ គក្រ និងជីប៉ូតាស្យូម ៧៥គក្រ ប្រើលាយជាមួយជីធម្មជាតិ ដាក់ ៣ដង ក្នុង១វដ្តជីវិតរបស់ស្រូវ ដូចខាងក្រោម:

***បាចលើកទី ១ . បាចទ្រាប់បាតមុនពេលស្ទូង***

.ប្រើជីធម្មជាតិពី ៥ -១០ តោន បាចលាយជីអ៊ុយរ៉េ ចំនួន១៦ គក្រ ជីដេអាប៉េចំនួន ៨៧គក្រ និងប៉ូតាសចំនួន ២៥គក្រ លើផ្ទៃដី ១ហ.ត ។

***បាចលើកទី ២. បាចបំប៉ន ក្រោយពេលស្ទូង ២៥ ទៅ ៣០ថ្ងៃ***

.អ៊ុយរ៉េ ចំនួន ៣៥គក្រ

***បាចលើកទី ៣ បាចបំប៉ន ក្រោយបាចជីលើកទី២ ពី ១៥ ទៅ ២០ថ្ងៃ***

.អ៊ុយរ៉េ ចំនួន ២៦ គក្រ និងប៉ូតាស ចំនួន ២៥គក្រ

**-ដីក្រុមបាកាន** ប្រើជីអ៊ុយរ៉េ ចំនួន ១៥០គក្រ ជីដេអាប៉េ ៦៥គក្រ និងជីប៉ូតាស្យូម ៥០គក្រ ប្រើលាយជាមួយ ជីធម្មជាតិបាច ៣ដង ក្នុង ១វដ្តជីវិតរបស់ស្រូវ ដូចខាងក្រោម

***បាចលើកទី ១ បាចទ្រាប់បាតមុនពេលស្ទូង***

.ប្រើជីធម្មជាតិពី ៥ -១០តោន អ៊ុយរ៉េ ចំនួន ៣០ គក្រ ដេអាប៉េចំនួន ៦៥គក្រ និងប៉ូតាស ៥០គក្រ

***បាចលើកទី ២*** បាចបំប៉នក្រោយពេលស្ទូង ២៥ ទៅ ៣០ ថ្ងៃ ប្រើជី អ៊ុយរ៉េ ចំនួន ៧០ គក្រ

***បាចលើកទី ៣*** បាចបំប៉ន ក្រោយបាចជីលើកទី២ ពី ១៥ទៅ ២០ថ្ងៃ ប្រើជីអ៊ុយរ៉េ ចំនួន ៥០គក្រ

- **ប្រសិទ្ធិភាពនៃការបាចជី**

-ត្រូវប្រើប្រាស់ជីអោយបានត្រឹមត្រូវតាមដំណាក់កាលនិមួយៗដែលស្រូវត្រូវការ

-ត្រូវបាចជីមុនពេលស្ទូងដោយបង្កប់ជីអោយចូលទៅក្នុងដីមិនត្រូវបង្ហើរជីដោយមិនបង្កប់វាទេឬ មិនត្រូវបាចជី ក្នុងទឹកក្រោយពីស្ទូងរួចភ្លាមទេ ។

-ត្រូវធ្វើស្មៅក្នុងស្រែអោយស្អាតមុនបាចជី

-ការបាចជីជាការល្អ ស្រែត្រូវមានទឹកជំរៅ ៥ស.ម

-ការប្រើប្រាស់ជីត្រូវគិតគូរពីតុល្យភាពជីអាហ្សូត ហ្វូស្វាត និងប៉ូតាស្យូមហើយប្រើបរិមាណជីអោយបានគ្រប់គ្រាន់ នោះគេនឹងទទួលដើមបែកប្រសើរបំផុត ផ្លែស្លឹកល្អ និងទិន្នផលខ្ពស់ ។

-ជៀសវៀងកុំបាចជីពេលស្លឹកស្រូវនៅសើម ហើយក៏មិនត្រូវបាចជីនៅពេលមានភ្លៀងខ្លាំងដែរ។

## ៥. គ្រប់គ្រងទឹកតាមដំណាក់កាលលូតលាស់របស់ស្រូវ

ស្រូវជាដំណាំត្រូវការទឹកខ្លាំង ជាពិសេសនៅវគ្គបង្កបង្កើតផល (ចាប់ពីដំណាក់កាលកំណកំណើតកួរ រហូតដល់ដាក់ទឹកដោះ)។ ការធ្វើឱ្យមានទឹកដក់ជាប្រចាំនៅក្នុងស្រែជាមធ្យោបាយមួយដើម្បីបន្ថយនូវហេតុការណ៍ទាំងឡាយដូចជា ការដែលដើមស្រូវអាចអន់កំលាំង និង បាត់បង់ទិន្នផល ព្រមទាំងជួយទប់ស្កាត់ការដុះលូតលាស់ នៃស្មៅចង្រៃ និង ជួយបង្កើនប្រសិទ្ធិភាពនៃជីក្នុងការស្រូបយកជីជាតិអាសូត ។

➢ **កំរិតទឹកដែលត្រូវដាក់លើដំណាំស្រូវ**

- ពេលស្ទូង ៥ស.ម
- ក្រោយស្ទូង ១០ថ្ងៃ ៥ស.ម-១០ស.ម
- ពេលស្រូវកំពុងបែកគុម្ព ១០ស.ម និងក្រោយមកបើមានលទ្ធភាពត្រូវបង្ហូរទឹកចេញរយះពេល ៥-៧ថ្ងៃដើម្បីឱ្យមានខ្យល់ចូលទៅក្នុងដីងាយស្រូវស្រូបយក រួចទើបបញ្ចូលទឹកកំរិត ១០ស.មវិញ។

-ពេលស្រូវបែកគុម្ពខ្លាំង (១៥ដើម -២០ដើម )ត្រូវបញ្ចូលទឹកកំរិត ២០ស.ម ដើម្បីបន្ថយការចេញក្លៀងស្រូវបន្ថែមទៀតដែលនាំឱ្យស្រូបយកជីឥតប្រយោជន៍ ។

-ពេលស្រូវចេញផ្កាអស់ទើបត្រូវបន្ថយទឹកចេញម្តងបន្តិច១ រហូតដល់ស្រូវចាប់ផ្តើមទុំស្លាបសេកទើបបង្ហូរទឹកអស់ចេញពីស្រែតែម្តង។

## ៦. ស្មៅ និងការកំចាត់

ស្មៅមានច្រើនប្រភេទដែលមានដុះនៅតាមវាលស្រែដូចជា ស្មៅបែកក្បាល ស្មៅពុកបង្កង ស្មៅជើងក្រាស់ ស្មៅបារាំង ស្មៅចិញ្ចៀន ស្មៅប្រមោយដំរី ផ្កាកទឹក កក់ ច្រាច់...សុទ្ធតែមានឥទ្ធិពលអាក្រក់ដល់ដំណាំស្រូវដូចជា ជំរកសត្វល្អិតចង្រៃ ស្រូបយកជីជាតិ ពន្លឺ និងទឹកប្រជែងជាមួយស្រូវ ...... ដូច្នេះត្រូវមានវិធានការការពារកុំឱ្យដុះ និង កំចាត់ជាបន្ទាន់បើមានដុះនៅក្នុងស្រែ។

➢ **ការបង្ការទប់ទល់ និងការដុះស្មៅ**

-ពិនិត្យមើលគ្រាប់ពូជ គ្រាប់ពូជខ្លះអាចមានគ្រាបស្មៅនៅលាយឡំ

-ការភ្ជួររាស់ដីច្រើនសារធ្វើឱ្យដីធូរ និងគ្មានដុះស្មៅ ដីដែលភ្ជួររួចហាមកុំឱ្យគោ ក្របីចូលក្នុងស្រែព្រោះលាមកសត្វអាចមានគ្រាប់ស្មៅដែលអាចដុះបាន។

-ពេលស្ទូងរួចត្រូវរក្សាទឹកឱ្យមានជាប្រចាំនៅក្នុងស្រែ កាលណាដីគោកស្មៅនឹងមានលទ្ធភាពដុះភ្លាម

- ស្ទូងចន្លោះគុម្ពសមស្របតាមការណែនាំ ពេលស្ទូងមានទឹក សន្ទូងនឹងដុះលឿនហើយបែកគុម្ពជិតធ្វើឱ្យស្មៅពុំអាចដុះបាន។

- បង្ការកុំឱ្យស្មៅដែលដុះអាចបង្កើតគ្រាប់បាន។

➢ **វិធានការកំចាត់ស្មៅ**

-ដកដោយដៃ ប្រើកំលាំងពលកម្ម តំរៀបជាជួរចុះដកក្នុងស្រែ ក្រោយស្ទូង ២សប្តាហ៍ ស្មៅដែលដកចេញត្រូវយកដាក់លើភ្លឺ ឬជាន់បង្កប់ទៅក្នុងដី ករណីស្ទូងត្រង់ជួរ អាចប្រើឧបករណ៍រុញស្មៅ បង្កប់ទៅក្នុងភក់។

-ថ្នាំសំលាប់ស្មៅ មានថ្នាំសំលាប់ស្មៅច្រើនប្រភេទ ដែលមានប្រសិទ្ធិភាពកំចាត់ស្មៅ តែប្រើត្រូវធ្វើការកត់សំគាល់ជាមុន ឧទាហរណ៍ ថ្នាំគ្លីហ្វូស៊ាត (Glyphosate ) គេប្រើដោយបាញ់លើដីមុនធ្វើការសាបព្រោះ ថ្នាំប៊ុយតាក្លរ (Butachlor)គេប្រើមុនស្មៅដុះថ្នាំខ្លះគេប្រើសំរាប់ស្រែមានទឹកនិងខ្លះទៀតសំរាប់ដីគោកនិងប្រភេទស្មៅផ្សេងៗគ្នា។

## ៧.ការកំចាត់សត្វល្អិត

ក្នុងឯកសារនេះ យើងសូមលើកយកសត្វមមាចត្នោត ដោយសារកសិករជួបបញ្ហាជារៀងរាល់ឆ្នាំ ហើយការបំផ្លាញអាចធ្វើឱ្យខូចខាតធ្ងន់ធ្ងរបើពុំមានវិធានការកំចាត់ទាន់ពេលវេលា។

## សត្វមមាចត្នោត

### ១. អ្វីទៅជាមមាចត្នោត?

មមាចត្នោតជាសត្វល្អិតចង្រៃនៃដំណាំស្រូវមានខ្លួនតូចទំហំប៉ុនគ្រាប់អង្ករ និង មានពណ៌ត្នោតនៅពេលពេញវ័យ។ វដ្តជីវិតរបស់មមាចត្នោតមានរយៈពេល៣៥ថ្ងៃ។ នៅពេលពេញវ័យមមាចត្នោតញី កាត់ជាមួយមមាចត្នោតឈ្មោលរួចពងរហូតដល់វាងាប់។ មមាចត្នោតញីនិមួយៗអាចពងបានរហូតដល់ ១៥០ពង។ មមាចត្នោតញីជាកញ្ចុំៗ ហើយដែលមួយកញ្ចុំៗមានពងពី ៧-៨តម្រៀបគ្នាដូចស្អិតចេកនៅលើស្រទបស្លឹកស្រូវ។ បន្ទាប់ពីពងរួចបានប្រហែលមួយអាទិត្យកូនមមាចត្នោតនឹងញាស់។ កូនមមាចត្នោតញាស់ត្រូវឆ្លងកាត់ការសកចំនួន ៥ដង ដែលមានរយៈពេលប្រមាណជា ១៥ថ្ងៃ ទើបក្លាយជាមមាចត្នោតពេញវ័យ។ ជាទូទៅមមាចត្នោតពេញវ័យមានស្លាបខ្លី ប៉ុន្តែក្នុងករណីដែលវាត្រូវការផ្លាស់ទីជម្រកថ្មីសម្រាប់ចំណីនិងបន្តពូជ ពេលនោះស្លាបវានឹងដុះលូតលាស់វែងដែលអាចឱ្យវាហើរបម្លាស់ទីបាន។

### ២. តើការបំផ្លាញរបស់វាយ៉ាងដូចម្តេច?

កូនមមាចត្នោតទើបញាស់រហូតដល់ពេញវ័យ បំផ្លាញដំណាំស្រូវចាប់ពីសំណាបដល់ទុំ។ ប៉ុន្តែការបំផ្លាញនេះមានកម្រិតខ្លាំងក្លា ចំពោះកូនមមាចត្នោតជិតពេញវ័យ និងពេញវ័យ។ ការបំផ្លាញដំណាំស្រូវរបស់មមាចត្នោតមានពីរបែបគឺទីមួយជញ្ជក់យករុក្ខរសពីដើមស្រូវ រហូតដល់ដើមស្រូវខ្សោះ ខ្លោច ងាប់ និងទីពីរ គឺជាភ្នាក់ងារចម្លងជម្ងឺវីរុសពីរប្រភេទគឺជម្ងឺតឿស្មៅ និងជម្ងឺតឿរួញស្លឹក។ ជាទូទៅមមាចត្នោតច្រើនតែបំផ្លាញដំណាំស្រូវធ្ងន់ធ្ងរដោយជញ្ជក់យករុក្ខរសប៉ុណ្ណោះ។ ចំពោះជម្ងឺតឿស្មៅ និងតឿរួញស្លឹកភាគច្រើនកើតមានលើគុម្ពមួយចំនួនតូចក្នុងស្រែតែប៉ុណ្ណោះ។ ក្នុងករណីដែលសង្កេតឃើញមានគុម្ពស្រូវដែលកើតជម្ងឺទាំងពីរប្រភេទនេះត្រូវដកវាគរដុតចោលដើម្បីសម្លាប់វីរុស និងទប់ស្កាត់ការរីករាលដាល។

### ៣. តើយើងត្រូវធ្វើដូចម្តេចដើម្បីការពារកុំឱ្យមានការបំផ្លាញ

ខ្យល់អាកាសក្ដៅសើម និងហប់នៅក្នុងស្រែជាលក្ខខណ្ឌប្រកបសម្រាប់មមាចត្នោត។ ដូចនេះយើងត្រូវសម្អាតស្មៅក្នុងស្រែ និងតាមភ្លឺជាប់ជាប្រចាំដើម្បីឱ្យមានខ្យល់ចេញចូលបានល្អ។ ត្រូវថែរក្សាកង្កែបគ្រប់ប្រភេទពីងពាង អណ្ដើកមាស កន្ធុំរុយ ស្រីងគោក រួមទាំងត្រីក្នុងស្រែឱ្យបានច្រើន ព្រោះសត្វទាំងអស់នេះវាស៊ីពងមមាចត្នោតរហូតដល់មមាចត្នោតពេញវ័យ។ ត្រូវប្រើពូជស្រូវដែលធន់ទៅនឹងមមាចត្នោត។ ពូជស្រូវដែលធន់ទ្រាំមធ្យមគឺ អ៊ីរ៉ែរកេសរ គ្រូជលសារ និង ខា១២។ ត្រូវធ្វើដីដោយភ្ជួរលប់គល់ជញ្ជ្រាំងឱ្យរលួយបានល្អ និងមិនត្រូវផ្ដល់ឱ្យដំណាំស្រូវនូវសារធាតុចិញ្ចឹមអាសូតច្រើនជ្រុលពេកទេ ទោះបីជាសារធាតុអាសូតនោះបានមកពីប្រភពជីណាក៏ដោយ ព្រោះថាដំណាំស្រូវ ដែលមានសារធាតុ អាសូតច្រើនជ្រុល នឹងលូតលាស់ខុសប្រក្រតីធ្វើឱ្យជាលិកាស្លឹក និងដើមមានសភាពទន់ជ្រុល សមប្រកបសម្រាប់ការចាក់ជញ្ជក់យកចំណីព្រមទាំងរុក្ខរសមានបរិមាណជាតិស្ករហេតុធ្វើឱ្យមមាចត្នោតពងញាស់ និងសកទៅជាមមាចត្នោតពេញវ័យបានច្រើន។

## ៤.តើយើងត្រូវធ្វើដូចម្ដេច កុំឱ្យមានការរីករាលដាល

ការចុះត្រួតពិនិត្យស្រែជាប្រចាំនៅលើថ្នាលសំណាប និងស្រែសន្ទូង ឬពង្រួសក្នុងដំណាក់កាលស្រូវបែកគុម្ពរហូតដល់ដំណាក់កាលស្រូវដាក់គ្រាប់។ ការចុះត្រួតពិនិត្យត្រូវធ្វើជារៀងរាល់សប្ដាហ៍ ប៉ុន្តែបើឃើញមានវត្តមានមមាចត្នោតហើយត្រូវចុះតាមដាន ២-៣ ថ្ងៃម្ដង។

<u>**ថ្នាលសំណាបៈ**</u> បន្ទាប់ពីសង្កេតឃើញថាមានមេមមាចត្នោត ២-៣ជាច្រើនកន្លែងក្នុងថ្នាលសំណាបហើយ បីថ្ងៃក្រោយមកទៀតត្រូវចុះមកតាមដានបន្តនៅពេលនោះបើឃើញវត្តមានកូនមមាចត្នោតញាស់ស្មើ ឬច្រើនជាង១០ក្នុងផ្ទៃដីពីរតឹកបួនជ្រុងជាច្រើនកន្លែងត្រូវចាត់វិធានការណ៍កំចាត់ជាបន្ទាន់តាមជាក់ស្ដែង។ ក្នុងករណីដែលមានទឹកគ្រប់គ្រាន់ត្រូវបញ្ចូលទឹកពន្លិចដើមសំណាប ដោយទុកចុងស្លឹកឱ្យបានរយៈពេល ៧-៨ថ្ងៃ ដើម្បីកុំឱ្យកូន និងមេមមាចត្នោតអាចជញ្ជក់យករុក្ខរសបានព្រមទាំងមិនឱ្យពងរបស់វាញាស់បាន។ ក្នុងរយៈពេលពន្លិចទឹកនេះត្រូវឧស្សាហ៍ដើរគោះស្លឹកសំណាបទម្លាក់កូន និងមេមមាចត្នោតទៅក្នុងទឹករួចបង្ហូរវាចេញ ដោយដាក់ស្បៃមុងត្រងយកមកជាន់កម្ទេចចោល។ ក្នុងករណីដែលគ្មានទឹកការប្រើប្រាស់ថ្នាំពុលកសិកម្មសមស្របគឺជាការចាំបាច់។ ជាបឋមយើងត្រូវប្រើថ្នាំបាសា (Bassa) ដើម្បីសម្លាប់មេមមាចត្នោត។ មួយអាទិត្យក្រោយមកយើងត្រូវប្រើថ្នាំប៊ូទីល (Butyl=Applaud) ដើម្បីកុំឱ្យកូនមមាចត្នោតវាសកបានដូចនេះវានឹងងាប់។ ត្រូវចងចាំថាមិនត្រូវយកសំណាបដែលពោរពេញទៅដោយកូនមមាចត្នោតទៅស្ទូងឡើយ។

<u>**សន្ទូង ឬពង្រួសៈ**</u> ការតាមដានត្រូវធ្វើដូចលើថ្នាលសំណាបដែរ នៅពេលសង្កេតឃើញមមាចត្នោត និងកូនក្នុងមួយគុម្ព ឬពីរតឹកបួនជ្រុង (ពង្រួស) ហើយត្រូវបញ្ចូលទឹកពន្លិចដើមស្រូវទុកតែចុងស្លឹក ក្នុងករណីដែលអាចធ្វើបាន។ បន្ទាប់ពីបញ្ចូលទឹកហើយត្រូវឧស្សាហ៍ដើរគោះស្លឹកស្រូវទម្លាក់កូន និងមេមមាចត្នោត និងបញ្ចូលហ្វូងទា(បើមាន)ឱ្យចូលស៊ី។ ទន្ទឹមនឹងនោះត្រូវសម្អាតស្មៅតាមភ្លឺស្រែ និង ដើរកៀរយកមមាចត្នោតដែលអណ្ដែតមកទើរតាមកៀនភ្លឺមកជាន់កម្ទេចចោល ។ ករណីដែលមានមេមមាចត្នោតច្រើន ត្រូវយកស្បៃមុងមកអូសជាជំនួយ។ ក្នុងករណីដែលគ្មានទឹកបញ្ចូលត្រូវប្រើថ្នាំដូចខាងលើ។



ជម្ងឺតឿរួញស្លឹក



ជម្ងឺតឿស្មៅ

## ៨.ការប្រមូលផល

**តើពេលណាដែលយើងគួរធ្វើការច្រូតកាត់ស្រូវ?**



ស្រូវទុំ ៨០- ៨៥%



ស្រូវមានសំណើម ២០- ២៥%

ត្រូវបង្ហូរទឹកចេញពីស្រែអោយបានពី ៧ទៅ១០ថ្ងៃ មុនពេលប្រមូលផល ឬនៅពេលដែលពិនិត្យឃើញថាស្រូវមានភាពទុំពេញលេញដែលបានផ្លូវពណ៌ពីបៃតងទៅលឿងទុំ ហើយគ្រាប់ស្រូវមិនទុំពេក និងមិនខ្ចីពេកទេ ហើយគួរច្រូតកាត់នៅសំណើមពី ២០-២៥%។ ត្រូវពិនិត្យអោយឃើញថាដើមស្រូវ និងកួរស្រូវមានភាពស្ងួត និងមានភាពទុំពី ៨០-៨៥%។ ប្រសិនបើករណីដំណាំមានភាពសើមខ្លាំង ដូចជានៅពេលមានភ្លៀងធ្លាក់ រឺនៅពេលព្រឹកព្រលឹម គឺយើងគួរតែរង់ចាំឱ្យវាស្ងួតទឹកអស់សិនទើបធ្វើការច្រូតកាត់។ ការប្រមូលផលយឺតពេកបណ្តាលឱ្យគ្រាប់ស្រូវជ្រុះខ្ចាត់ខ្ចាយក្នុងស្រែច្រើន ឬស្ងួតជ្រុលធ្វើអោយងាយប្រេះស្រាំនៅពេលបោកបែនហើយគ្រាប់ស្រូវអាចបាក់នៅពេលកិនជាអង្ករ។ ការប្រមូលផលឆាប់ពេកបណ្តាលអោយគ្រាប់ស្រូវជាច្រើនទុំស្មើរដែលធ្វើអោយថយចុះនូវបរិមាណ និងគុណភាពអង្ករដើមដែលកិនបាន។

ដើម្បីឱ្យការច្រូតកាត់ស្រូវធ្វើឡើងបានសមស្របបំផុត គេមិនត្រូវគិតតែលើអាយុកាលរបស់ដំណាំដែលប្រែប្រួលទៅតាមប្រភេទពូជប៉ុណ្ណោះទេ ប៉ុន្តែគេក៏ត្រូវពិនិត្យមើលផងដែរនូវកំរិតទុំជាក់ស្តែងរបស់ស្រូវ។

